# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


## សេចក្តីអំពាវនាវ

លេខ ០៥/១០ ស.ខ.ក.ក.

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ជាខួបគំរប់៦១ឆ្នាំ (០៤-៦-១៩៤៩_០៤-៦-២០១០) នៃថ្ងៃឈឺចាប់បំផុត ក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជាតិខ្មែរ ដែលអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោម ឲ្យអាណានិគមវៀតណាម ត្រួតត្រារហូតសព្វថ្ងៃ ។ ចាប់ពីពេលនោះមក ទឹកដីកម្ពុជាក្រោម បានក្រាលទៅដោយសាច់ស្រស់ឈាមស្រស់នៃខេមរកុលបុត្រកុលធីតា ក្នុងការប្រយុទ្ធតស៊ូយ៉ាងស្វិតស្វាញ ដើម្បីភាពគង់វង្ស ពូជសាសន៍ សាសនា សិល្បៈ វប្បធម៌ អក្សរសាស្ត្រ និងទំនៀមទំលាប់ដ៏ល្អផូរផង់នៃប្រជាជាតិខ្មែរ ។

ដើម្បីឲ្យកូនខ្មែរគ្រប់រូបចងចាំនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏ជូរចត់នេះ និងសំដែងនូវការគោរព និងដឹងគុណចំពោះវីរភាពដ៏អង់អាចក្លាហាននៃវីរបុរសខ្មែរស្នេហាជាតិទាំងអស់ សហគមន៍ខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោក តែងតែប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ ចាប់ពីឆ្នាំ២០០០ ជារៀងរាល់ឆ្នាំរហូតមក ដើម្បីឧទ្ទិសកុសលប្រគេនថ្វាយ និងជូនព្រះវិញ្ញាណក្ខន្ធ ព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិទាំងនោះ មិនដែលខកខានម្តងណាឡើយ ។

ពិធីបុណ្យដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រ ដែលប្រព្រឹត្តិទៅដោយជោគជ័យបានជារៀងរាល់ឆ្នាំនោះគឺ ដោយសារការលះបង់ដ៏ធំធេង ប្រកបដោយមនសិការស្នេហាជាតិដ៏ឧត្តុង្គឧត្តមរបស់បងប្អូនរួមឈាមនៅគ្រប់ទិសទី ជាពិសេសបងប្អូនរួមឈាមនៅឯនាសមុទ្រតែម្តង ។ ឆ្នាំនេះក៏មិនខុសពីឆ្នាំមុនៗដែរ យើងខ្ញុំសូមលំអោនកាយគោរពនិងអំពាវនាវយ៉ាងទទូចបំផុតដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់មេត្តាជួយឧបត្ថម្ភគាំទ្រតាមសទ្ធាជ្រះថ្លាឲ្យបានគ្រប់ៗអង្គ និងគ្រប់ៗរូប ដើម្បីយើងខ្ញុំមានលទ្ធភាពរៀបចំពិធីបុណ្យឲ្យប្រព្រឹត្តិទៅដោយជោគជ័យដូចឆ្នាំមុនៗតាមការគួរ ។

សេចក្តីអំពាវនាវនេះទុកជាសេចក្តីនិមន្ត និងអញ្ជើញព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ និងសប្បុរសជនទាំងអស់មេត្តាចូលរួមឲ្យបានច្រើនកុះករ ដើម្បីញុំាងឲ្យកម្មវិធីបុណ្យជាប្រវត្តិសាស្ត្រនេះបានប្រព្រឹត្តទៅដោយជោគជ័យ ។

ការធ្វើវិភាគទាន និងការអញ្ជើញចូលរួមរបស់បងប្អូនរួមជាតិ គឺជាការសំដែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវីរមហាក្សត្រ និងវីរបុរស-នារី យុទ្ធជន-យុទ្ធនារីខ្មែរស្នេហាជាតិ និងបានជាប្រយោជន៍ដ៏ធំធេងដល់ប្រជារាស្ត្រ និងមាតុភូមិខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ ។

កម្មវិធីបុណ្យ នឹងប្រព្រឹត្តទៅក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ចាប់ពីម៉ោង៧:៣០នាទីរហូតដល់ម៉ោង១១:៣០នាទីថ្ងៃត្រង់ នាសួនច្បារខាងមុខវត្តបុទុមវតី រាជធានីភ្នំពេញ ។

គណៈកម្មការបុណ្យសូមថ្លែងអំណរព្រះគុណ និងអរគុណទុកជាមុនចំពោះស្មារតីស្នេហាជាតិ និងសទ្ធាជ្រះថ្លារបស់បងប្អូនរួមជាតិ និងសូមឲ្យបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

*សូមអរព្រះគុណ និងអរគុណ*

!

*រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១០*

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

ក្រុមប្រឹក្សារាជធានីភ្នំពេញ

អតីតសមាជិកព្រឹទ្ធសភា


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៧៧ ០០៧

E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org